ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 30 / 09 / 2015
ម៉ោង (Time/Heure): 09 : 30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# អង្គជំនុំជម្រះសាលាដំបូង

សាធារណៈ / Public

ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៥

**ជូនចំពោះ៖** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំកែតម្រូវ និង បន្ថែមឯកសារពាក់ព័ន្ធនឹងប្រធានកងចល័តតំបន់ ៥ តា វ៉ាល់ និង លេខាតំបន់ ៥ ហេង រិន

១. ក្រោយពីកិច្ចពិភាក្សាដែលបានធ្វើឡើងនៅក្នុងអំឡុងពេលសវនាការនាថ្ងៃទី ១២ និង ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៥ អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើសុំមួយដែលសហព្រះរាជ-អាជ្ញាបានដាក់ជូនកាលពីថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៥ (ឯកសារ E357) ("សំណើសុំ")។ អនុលោមតាមវិធាន ៨៧(៣) និង (៤) នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាបានស្នើសុំ "កែតម្រូវ និង បន្ថែម" ឯកសារចំនួនពីរដែលអង្គជំនុំជម្រះបានទទួលយកសម្រាប់ជាឯកសារ ភ័ស្តុតាងក្នុងសំណុំរឿង ០០២/០២ រួចហើយ៖ ឯកសារ E3/1900 (បញ្ជីឈ្មោះអ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ ដែលត្រូវបានកម្ទេចកាលពីថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ១៩៧៨) និង ឯកសារ E3/7403 (ចម្លើយសារភាពពីមន្ទីរសន្តិសុខ ស-២១ របស់ ហេង រិន ហៅ មុី)។ លើសពីនេះទៀត សហព្រះរាជអាជ្ញាក៏បានស្នើសុំឲ្យទទួលយកមកដាក់បញ្ចូលធ្វើជាឯកសារ ភ័ស្តុតាងចំពោះឯកសារចំនួនពីរដែលអាចជួយបញ្ជាក់ការពិត៖ បញ្ជីឈ្មោះអ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ នៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៧ និង ចម្លើយសារភាពនៅមន្ទីរសន្តិសុខ ស-២១ របស់ អោក ហ៊ិន ហៅ វ៉ាត ប្រធានកងចល័ត តំបន់ ៥ ភូមិភាគពាយ័ព្យ (ឯកសារ E357 កថាខណ្ឌ ៣ រួមជាមួយនឹងឧបសម្ព័ន្ធ ២ និង ៣ ដោយឡែកពីគ្នា)។ សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា ឯកសារចំនួនពីរក្រោយនេះ "មិនមែនជាឯកសារថ្មី" នោះទេ ដោយសារថា ឯកសារទាំងពីរនេះត្រូវ

បានរកឃើញនៅពេលកំពុងស្វែងរកសំណៅដើមជាភាសាខ្មែរនៃឯក-សារ E3/1900 និង សំណៅដែលត្រឹមត្រូវនៃឯកសារ E3/7403 (ឯកសារ E357 កថាខណ្ឌ ៣, ៥)។ ទោះបីជាយ៉ាងនេះក្តី សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា ឯកសារទាំងនេះពាក់ព័ន្ធនឹងសម្ភារៈដែលមានរួចហើយនៅក្នុងសំណុំរឿង និង ដែលផលប្រយោជន៍នៃយុត្តិធម៌តម្រូវឱ្យប្រភពទាំងនោះត្រូវយកមកធ្វើការវាយតម្លៃជាមួយគ្នា (ឯកសារ E357 កថាខណ្ឌ ៥)។ សហព្រះរាជអាជ្ញាបានលើកឡើងទៀតថា ឯកសារទាំងពីរនេះជាប់ពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ ជាពិសេស អង្គហេតុទាក់ទងនឹងមន្ទីរសន្តិសុខ ស-២១ និង ការដ្ឋានការងារទំនប់ត្រពាំងថ្ម (ឯកសារ E357 កថា-ខណ្ឌ ១, ៦)។ ពុំមានភាគីណាមួយបានដាក់ចម្លើយតបទៅនឹងសំណើសុំនេះឡើយ។

២. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង នៅគ្រប់ដំណាក់កាលនៃនីតិវិធីទាំងអស់ អង្គជំនុំជម្រះសាលាដំបូង អាចទទួលយកភស្តុតាងដែលខ្លួនយល់ឃើញថា អាចជួយដល់ការបញ្ជាក់ការពិត ក្នុងករណីភស្តុតាងទាំងអស់នោះបានបំពេញបទដ្ឋាន *បឋម*នៃភាពពាក់ព័ន្ធ ភាពអាចទុកចិត្តបាន និង យថាភាព ទៅតាមលក្ខខណ្ឌតម្រូវអនុលោមតាមវិធាន ៨៧(៣) នៃវិធាន ផ្ទៃក្នុង (ឯកសារ E319/7 កថាខណ្ឌ ៨)។ អង្គជំនុំជម្រះនឹងសម្រេចអំពីសំណើសុំទទួលយក ភស្តុតាងថ្មីស្របតាមលក្ខណៈវិនិច្ឆ័យដូចមានចែងនៅក្នុងវិធាន ៨៧ (៣) នៃវិធានផ្ទៃក្នុង។ វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងក៏តម្រូវឱ្យភាគីដែលបានស្នើសុំឱ្យទទួលយកភស្តុតាងថ្មី ត្រូវដាក់សំណើសុំដែលមានសំអាងហេតុត្រឹមត្រូវ។ ភាគីស្នើសុំត្រូវធ្វើយ៉ាងណាឱ្យអង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា ភស្តុតាងស្នើឡើងពុំអាចរកបាននៅមុនពេលចាប់ផ្តើមការជំនុំជម្រះ ឬ មិនអាចរកឃើញបើទោះជាបានខិតខំព្យាយាមយ៉ាងសមស្របហើយក៏ដោយ។ ទោះបីជាយ៉ាងនេះក៏ដោយ នៅក្នុងករណីមួយចំនួន អង្គជំនុំជម្រះបានទទួលយកភស្តុតាងនានា ទោះបីជាវាពុំបានបំពេញតាមលក្ខណៈវិនិច្ឆ័យនេះក៏ដោយ រួមទាំង នៅក្នុងករណីនានាដែលភស្តុតាងជាប់ ពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងសម្ភារៈដែលមានស្រាប់រួចហើយនៅចំពោះមុខអង្គជំនុំជម្រះ និងក្នុងករណីដែលផលប្រយោជន៍នៃយុត្តិធម៌តម្រូវឱ្យប្រភពទាំងនោះត្រូវយកមកធ្វើការវាយតម្លៃរួមគ្នា ឬ ករណីដែលឯកសារស្នើសុំជាឯកសារដោះបន្ទុក និង តម្រូវឱ្យវាយតម្លៃដើម្បីជៀសវាងកំហុសក្នុងការស្វែងរកយុត្តិធម៌ ឬ នៅក្នុងករណីដែលភាគីផ្សេងទៀតពុំជំទាស់ទៅនឹង ភស្តុតាងទាំងនេះ (ឯកសារ E276/2 កថាខណ្ឌ ២ យោងលើឯកសារ E190 និង ឯកសារ E172/24/5/1។ ឯកសារ E260 កថាខណ្ឌ ៥)។

៣. ចំពោះសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យទទួលយកបញ្ជីឈ្មោះអ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ ក្នុងខែ មិថុនា ឆ្នាំ ១៩៧៧ និង ចម្លើយសារភាពនៅមន្ទីរសន្តិសុខ ស-២១ របស់ អោក ហ៊ិន ហៅ វ៉ាត ប្រធានកងចល័ត តំបន់ ៥ ភូមិភាគពាយ័ព្យ អង្គជំនុំជម្រះពិចារណាឃើញថា ឯកសារទាំងពីរនេះអាចរកបាននៅពេលចាប់ផ្តើមការជំនុំជម្រះ និង ប្រហែលជាអាចទំនងរកឃើញនៅមុននោះទៅទៀត ប្រសិនបើបានខិតខំព្យាយាមរកឱ្យបានសមស្រប។ អាស្រ័យហេតុនេះ សំណើសុំត្រង់បញ្ហានេះពុំបានធ្វើឡើងឱ្យបានទាន់ពេលវេលានោះឡើយ។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះពិចារណាឃើញថា ការទទួលយកឯកសារទាំងពីរនេះមកដាក់បញ្ចូលដើម្បីធ្វើជាឯកសារភ័ស្តុតាងអាចបំពេញបន្ថែមលើភ័ស្តុតាងដែលបានស្រាប់រួចហើយ ដោយសារថា ឯកសារចំនួនពីរនេះជាប់ពាក់ព័ន្ធយ៉ាងជិតស្និទ្ធនឹងឯកសារ E3/1900 និង ឯកសារ E3/7403 ក្នុងចំណោមឯកសារផ្សេងទៀត។ ឯកសារទាំងឡាយដែលពាក់ព័ន្ធនឹងការចាប់ខ្លួន ការឃុំខ្លួន និង ការធ្វើបាបអ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ ជាពិសេស កម្មា- ភិបាលតំបន់ ៥ ដែលជាអង្គហេតុមួយក្នុងចំណោមអង្គហេតុនានា គ្រោងនឹងយកមកដេញដោលនៅក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២ នាពេលខាងមុខ។ ផ្អែកលើចំណុចដូចបានរៀបរាប់ខាងលើនេះ និង ដោយហេតុថា គ្មានភាគីណាមួយជំទាស់នឹងសំណើសុំនេះ អង្គជំនុំជម្រះពិចារណាឃើញថា ការទទួលយកឯកសារទាំងពីរនេះគឺក្នុងគោលបំណងដើម្បីជាផលប្រយោជន៍នៃយុត្តិធម៌ ហើយវានឹងអាចជួយដល់ការបញ្ជាក់ការពិតបាន។

៤. ពាក់ព័ន្ធនឹងឯកសារ E3/7403 (ចម្លើយសារភាពនៅមន្ទីរសន្តិសុខ ស-២១ របស់ ហេង រិន ហៅ ម៉ី) ដូចក្រុមមេធាវីការពារក្តី ខៀវ សំផន បានកត់សម្គាល់នៅក្នុងអំឡុងពេលសវនាការនាថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៥ សំណៅភាសាខ្មែរនៃឯកសារនេះ តាមពិតទៅគឺជាចម្លើយសារភាពរបស់បុគ្គលផ្សេងម្នាក់ទៀតដែលមានឈ្មោះដូចគ្នានឹងឈ្មោះលេខាតំបន់ ៥ ហេង រិន (ឯកសារ E1/330.1 ទំព័រ ៧៤)។ អង្គជំនុំជម្រះពិចារណាឃើញថា សំណើសុំយកឯកសារត្រឹមត្រូវ (ឯកសារ E357 កថាខណ្ឌ ៤ និង ឧបសម្ព័ន្ធ ៤) មកជំនួសឯកសារនេះវិញទាក់ទងនឹងការកែតម្រូវលើកំហុសរដ្ឋបាលតែប៉ុណ្ណោះ។ វាពុំមែនជាសំណើសុំអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងនោះទេ។ ដោយហេតុថា គ្មានភាគីណាមួយជំទាស់ទៅនឹងសំណើសុំត្រង់ផ្នែកនេះ អង្គជំនុំជម្រះពិចារណាឃើញថា ជាការសមស្របក្នុងការយកឯកសារសំណៅភាសាខ្មែរត្រឹមត្រូវមកជំនួសសំណៅឯកសារភាសាខ្មែរបច្ចុប្បន្នលេខ E3/7403។

៥. ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះពិចារណាឃើញថា វិធាន ៨៧(៣) និង (៨៤) មិនអាចយកមកអនុវត្តបានចំពោះសំណើរបស់សហព្រះរាជអាជ្ញាសុំយកសំណៅដើមជាភាសាខ្មែរនៃឯក-សារលេខ E3/1900 (បញ្ជីឈ្មោះអ្នកជាប់ឃុំដែលត្រូវបានកំទេចនៅមន្ទីរសន្តិសុខ ស-២១ នាថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ១៩៧៨) មកដាក់បន្ថែមលើសំណៅបកប្រែជាភាសាអង់គ្លេស និងបារាំង ដែលមាននៅក្នុងសំណុំរឿងរួចស្រេចហើយទេ (ឯកសារ E357 កថាខណ្ឌ ១ និងឧបសម្ព័ន្ធ ១)។ អង្គជំនុំជម្រះសូមរំលឹកឡើងវិញថា នៅក្នុងអំឡុងពេលសវនាការនាថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៥ ក្រោយពីចៅក្រម Lavergne ស្នើសុំឱ្យបញ្ជាក់បំភ្លឺថា តើសំណៅដើមជាភាសាខ្មែរនៃឯកសារ E3/1900 មានដែរ ឬ ទេ ការិយាល័យសហព្រះរាជអាជ្ញាបានឆ្លើយតបថា ការិយាល័យសហព្រះរាជអាជ្ញាកំពុងសាកសួរលើបញ្ហានេះ ហើយសេចក្ដីសន្និដ្ឋាន ជាលាយលក្ខណ៍អក្សរនឹងដាក់ជូននៅពេលសមស្របខាងមុខ (ឯកសារ E1/329.1 ទំព័រ ២-៤)។ ដោយសារថា សំណៅបកប្រែជាភាសាអង់គ្លេស និងបារាំងត្រូវបានទទួលយក ហើយក៏ត្រូវបានវាយតម្លៃអនុលោមតាមវិធាន ៨៧(៣) រួចហើយផងដែរនោះ (ឯកសារ E185/1.3 ឧបសម្ព័ន្ធ ៣ ទំព័រ ១១) អង្គជំនុំជម្រះពិចារណាឃើញថា សំណៅដើមជាភាសាខ្មែរនៃ ឯកសារនេះអាចទទួលយកបានតែម្តងដោយពុំចាំបាច់ត្រូវការពិនិត្យបន្ថែមនោះឡើយ។

៦. អនុស្សរណៈនេះ គឺជាចម្លើយតបផ្លូវការរបស់អង្គជំនុំជម្រះចំពោះឯកសារ E357។